ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា មានគោលបំណងស្តារសេដ្ឋកិច្ចកម្ពុជាក្នុងពេលចំពោះមុខ និងរយៈពេលមធ្យម ឱ្យត្រលប់ទៅកំណើនសក្តានុពល និងពង្រឹងភាពធន់សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាប័ន្ន ក្នុងរយៈពេលវែង។

ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា មានចក្ខុវិស័យ (១) ពង្រឹងការកសាងមាគ៌ា និងជវភាព នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយភាពរឹងមាំ (២) ចាប់យកកាលានុវត្តភាព ទាំងក្នុង និងក្រៅប្រទេស ដើម្បីកែលម្អមូលដ្ឋានសេដ្ឋកិច្ចជាតិឱ្យមានភាពប្រកួតប្រជែង និងពិពិធកម្មខ្ពស់ (៣) ព្រមទាំងលើកកម្ពស់សុខុមាលភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាឱ្យស្របទៅនឹងប្រក្រតីភាពថ្មីនៃការអភិវឌ្ឍ។ ក្របខណ្ឌយុទ្ធសាស្ត្រនេះ ផ្តោតលើការលើកកម្ពស់ការប្រកួតប្រជែង និងការធ្វើពិពិធកម្មសេដ្ឋកិច្ច ប្រែក្លាយកម្ពុជាទៅជាសេដ្ឋកិច្ចដែលមានមូលដ្ឋានឧស្សាហកម្មរឹងមាំ និងសមត្ថភាពនាំចេញខ្ពស់ ព្រមទាំងផ្សារភ្ជាប់កាន់តែស៊ីជម្រៅជាមួយខ្សែច្រវ៉ាក់ផ្គត់ផ្គង់តំបន់ និងពិភពលោក។

# សសរស្តម្ភចំនួន ០៣ (3Rs)៖

## 1 ការស្តារឡើងវិញ

តាមរយៈការកសាងឡើងវិញនូវមូលដ្ឋានគ្រឹះដ៏រឹងមាំនៃសេដ្ឋកិច្ច ដើម្បីត្រលប់ទៅរកមាគ៌ានៃកំណើន ដោយផ្តោតលើការធានាសុវត្ថិភាព ការគ្រប់គ្រងលើវិស័យដែលទទួលរងផលប៉ះពាល់ និងការបង្កើតការងារបន្ថែមឱ្យបានច្រើន និងឆាប់រហ័ស។

- វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម
- វិស័យទេសចរណ៍
- វិស័យកាត់ដេរ
- វិស័យកម្មន្តសាល មិនមែនកាត់ដេរ

## 2 ការកែទម្រង់

តាមរយៈការបន្តដាក់ចេញវិធានការកែទម្រង់សំខាន់ៗជារចនាសម្ព័ន្ធ ដែលរួមមាន ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាស និងកិច្ចសម្រួលពាណិជ្ជកម្មសម្រាប់ការវិនិយោគ និងធុរកិច្ច ក៏ដូចជាទាញយកផលប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលមានស្រាប់ សំដៅកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់កំណើន ពិពិធកម្ម និងភាពប្រកួតប្រជែង។

- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់
- ការជំរុញការអនុវត្តច្បាប់វិនិយោគ
- វិស័យអគ្គិសនី
- ការកែលម្អបរិយាកាសវិនិយោគ
- វិស័យដឹកជញ្ជូន និងឡូជីស្ទីក

## 3 ការកសាងភាពធន់

តាមរយៈការពង្រឹងការត្រៀមខ្លួន និងការឆ្លើយតប ដើម្បីធានាបាននូវចីរភាព និងបរិយាប័ន្ននៃការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ក៏ដូចជាទប់ទល់នឹងជំងឺ ឬវិបត្តិស្រដៀងគ្នាដែលអាចផ្ទុះឡើងនាពេលអនាគត ដោយផ្តោតលើការកសាងធនធានមនុស្ស និងជំរុញផលិតភាព ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ការចាប់យកឱកាសនៃវិស័យឌីជីថល ការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម។

- វិស័យឌីជីថល
- ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម
- ការអភិវឌ្ឍជំនាញ
- ការអភិវឌ្ឍវិស័យអប់រំ
- ប្រព័ន្ធគាំពារសង្គម
- ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- វិស័យសុខាភិបាល
- ការអភិវឌ្ឍបៃតង